# បច្ចេកទេសដាំដុះដំណាំដំឡូងមី



ដំឡូងមី ជាប្រភេទដំណាំយកមើម មានប្រភពដើមកំណើតពីទ្វីបអាមេរិក ។ បច្ចុប្បន្ន មានដាំនៅអាមេរិកឡាទីន និងនៅទ្វីបអាស៊ីអគ្នេយ៍ ។ ដោយឡែក នៅក្នុងប្រទេសកម្ពុជាយើង ដំណាំដំឡូងមី ជាដំណាំអាហារមួយប្រភេទ ដែលអាចហូបជំនួសបាយបាន នៅពេលអ្នកខ្វះអង្ករ ។ ក្រៅពីធ្វើជាអាហាររបស់មនុស្សគេអាចយកទៅធ្វើជាចំណីសត្វបានយ៉ាងល្អ ស្លឹកដំឡូងមី គេអាចយកទៅធ្វើជាបន្លែស្រស់ អន្លក់ ។ល។ គេអាចយកម្សៅដំឡូងមី ធ្វើជានំប៉ុងជំនួសស្រូវសាឡីបាន ជាងនេះទៅទៀត ដំឡូងមី ក៏ជាវត្ថុធាតុដើមរបស់រោងចក្រសម្រាប់ផលិតក្រដាស់ ឬ ជ័រ ។

## ១. ការដាំដុះ

កាត់ដើមដំឡូងមីធំចាស់ល្អនៅស្រស់ប្រវែងពី២០ទៅ ៤០ស.ម ដែលមានភ្នែកពី៤ ទៅ៦ ។ គេអាចដាំដំឡូងមីបានពីររបៀប ៖



របៀបទី ១ : កាប់ជារណ្តៅទំហំកន្លះម៉ែត្របួនជ្រុង និងជំរៅកន្លះម៉ែត្រ ហើយក្នុងរណ្តៅត្រូវដាក់ជីកំប៉ុស្ត ឬជីធម្មជាតិ រួចច្របល់នឹងដីបាតរណ្តៅ ។ បន្ទាប់មកយកដើមដែលកាប់ខ្លីៗទៅកប់ក្នុងរណ្តៅរាងបញ្ឈរត្រង់ ឬរាងទ្រេតបញ្ឆិតបន្តិច ឬកប់ដីបាតតែម្តង ។ គេច្រើនអនុវត្តរបៀបនេះនៅរដូវប្រាំង ។



របៀបទី ២ : លើកជារងដែលមានទទឹង ១ ម៉ែត្រ និងកំពស់ពី២០ ទៅ ៣០ស.ម ។ បន្ទាប់មកកាប់ជារណ្តៅតូចលើរង រួចកប់ដើមដំឡូងតាមរបៀបដាំទី១អញ្ចឹងដែរ ។

ការដាំដំឡូងមីត្រូវទុកចន្លោះជួរ ឬរង ១ម៉ែត្រ និងចន្លោះគុម្ពពី ៣០ ទៅ ៤០ ស.ម ។ ក្រោយពេលដាំរួចត្រូវស្រោចទឹករហូតដល់ដុះពន្លក ។ ដំណាក់កាលនេះពុំសូវត្រូវការទឹកណាស់ណាទេ ។

## ២. លក្ខខណ្ឌដី និងអាកាសធាតុសមស្រប

### ក. សីតុណ្ហភាព

លក្ខខណ្ឌសមស្របសំរាប់ដំឡូងមីឬដំឡូងឈើគឺអាកាសធាតុសើមហើយក្តៅល្មម (២៥-៣០ អង្សាសេ)។ ដំឡូងមីមិនអាចដុះលូតលាស់បាននៅតំបន់ដែលមានសីតុណ្ហភាពក្រោម១០អង្សាសេឡើយ ។ តែបើសីតុណ្ហភាពឡើងខ្ពស់ ឬក្តៅពេកនោះ ទិន្នផលក៏ត្រូវថយចុះដែរ។ នៅប្រទេសកម្ពុជា ដំឡូងមីដុះលូតលាស់ ល្អ និងទិន្នផលខ្ពស់នៅដើមរដូវប្រាំង គឺក្នុងខែវិច្ឆិកា-ធ្នូ ។

### ខ. ទឹកភ្លៀង

ដំណាំដំឡូងមីដុះលូតលាស់បានល្អប្រសើរ ក្នុងកំរិតទឹកភ្លៀងកំពស់ពី ១០០០ ទៅ ១៥០០ ម.ម ប៉ុន្តែវាក៏អាចដុះលូតលាស់បាន នៅតំបន់ដែលមានទឹកភ្លៀង កំពស់លើសពី ៥០០ម.ម ឬក្រោម២៥០០ម.ម បានដែរ ព្រោះដំឡូងមីជាដំណាំដែលអាចធន់ទ្រាំទៅនឹងការប្រែប្រួលរបស់ធម្មជាតិ ។

### គ. ពន្លឺ

ដំណាំដំឡូងមីត្រូវការពន្លឺថ្ងៃរយៈពេលខ្លី ដើម្បីឲ្យមើមវារីកធំធាត់ល្អនិងផ្តល់ទម្ងន់ធ្ងន់ ។ ទិន្នផលមើមទាបនៅពេលពន្លឺថ្ងៃមានរយៈពេលវែងលើសពី១២ម៉ោងក្នុងមួយថ្ងៃ ។

### ឃ. ដី

ដំឡូងមីពុំសូវរើសដីទេ ប៉ុន្តែដីដែលល្អហើយសមស្របជាងគេ គឺដីល្បាយខ្សាច់ ធូរ ហើយស្រោះទឹកល្អ និងមានជីជាតិ ។ នៅតំបន់ប្រភេទដីឥដ្ឋ ដំឡូងមីពុំសូវផ្តល់ទិន្នផលខ្ពស់ និងមានមើលតូចៗ ។

### ង. ជី

ដំឡូងមីត្រូវការជីជាតិប៉ូតាស្យូមច្រើនដើម្បីបង្កើនជាតិម្សៅរបស់មើម ។ការដាក់ជីហួសកំរិតពេកអាចបណ្តាលឱ្យអ្នក

ដាំខាតបង់ថវិកា កម្លាំងពលកម្ម ព្រោះវាធ្វើឱ្យដើមដងដុះលូតលាស់ល្អពេក តែមើមស្រាល ឯទិន្នផលក៏ថយចុះ។

## ៣. ការថែទាំ

### ក. ការជ្រួយដីពូនគល់ និងបោចស្មៅ

ត្រូវជំរះស្មៅ ជ្រួយដីឱ្យបានញឹកញាប់ពេលដើមដំឡូងមីនៅតូចៗ ត្រូវពូនគល់ក្រោយពេលដាំរយៈពេល ២-៣ ខែដើម្បីជួយទប់ដើមមិនឱ្យរលំដួល ហើយផ្តល់មើមធំៗ ។ ការងារនេះសំខាន់ណាស់ គឺធ្វើឲ្យដីធូរ ខ្យល់ចេញចូលបានល្អ ងាយស្រួលក្នុងការចាក់ឫសធ្វើឱ្យដើមដងរឹងមាំ ។

### ខ. ការលួសស្លឹក

គេអាចលួសស្លឹកខាងក្រោមចេញខ្លះ នៅពេលដែលវាមានកំពស់ពី៨០ទៅ១០០ ស.ម ដើម្បីឱ្យដើមដងដុះធំធាត់ល្អ ។

### គ. របៀបប្រើជីទ្រាប់បាត :

- ជីលាមកសត្វពី ៦ ទៅ ៧ តោន ក្នុងមួយហិកតា
- ជី ១៥-១៥-១៥ ចំនួន ២០០គក្រ ក្នុងមួយហិកតា ។

## ៤. ជម្ងឺ

ជំងឺដែលច្រើនរាតត្បាតលើដំណាំដំឡូងមីគឺបណ្តាលមកពីវីរុស ( Mosaic virus ) ។

## ៥. សត្វល្អិត

សត្វល្អិតចង្រៃដែលបំផ្លាញលើដំណាំនេះមានពីងពាងក្រហម ។ ប្រភេទសត្វធំៗមួយចំនួនដូចជាជ្រូក និងសត្វពាហនៈផ្សេងៗ ។ ល។ ក៏បំផ្លាញដំណាំនេះដែរ ។

## ៦. ការប្រមូលផល

ដំណាំដំឡូងឈើពូជស្រាលអាចប្រមូលផលបានក្នុងរយៈពេលពី៥-៦ខែក្រោយពេលដាំ ។ លក្ខណៈសំគាល់គឺស្លឹកវាឡើងពណ៌លឿង ហើយចាប់ផ្តើមជ្រុះស្លឹកនៅគល់ដេញឡើងទៅលើ ។ មុនគាស់មើមត្រូវកាប់ដើមចេញសិន ដោយទុកប្រហែល ៣០-៤០ ស.ម ពីដី ។

ចំពោះដំឡូងមីពូជធ្ងន់អាចប្រមូលផលបានក្នុងរយៈពេល ១ឆ្នាំ ឬលើសពី១ឆ្នាំ ។ ការប្រមូលផលប្រែប្រួល ទៅតាមប្រភេទពូជ និងសេចក្តីត្រូវការរបស់អ្នកដាំ ។



### កំណត់សំគាល់

ការប្រមូលផលសំរាប់បំរើការហូបចុកអាចធ្វើទៅបានតាំងពីមើមដំឡូងនៅខ្ចី រហូតដល់ចាស់ ។ ប៉ុន្តែសំរាប់ បំរើនៅក្នុងរោងចក្រឧស្សាហកម្មវិញ ត្រូវទុកមើមឱ្យចាស់គ្រប់អាយុពេញលេញទើបប្រមូលផល ដើម្បីបង្កើនជាតិម្ស៉ៅបានច្រើន ។



ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម

# បច្ចេកទេសដាំដុះដំណាំដំឡូងមី



រៀបចំចងក្រងដោយៈ
នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម
ឆ្នាំ២០១៣

សម្រាប់ព័ត៌មានលម្អិតសូមទំនាក់ទំនងមកនាយកដ្ឋានផ្សព្វផ្សាយកសិកម្មតាមសយដ្ឋានខាងក្រោមៈ
លេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា ទូរស័ព្ទលេខ : (០២៣)-២១៥ ៨១៩/០១២ ៨២៦ ៦១៧

ឧបត្ថម្ភការបោះពុម្ពផ្សាយដោយៈ
គម្រោងកម្មវិធីខ្សែចង្វាក់ផលិតកម្មតម្លៃកសិកម្ម កម្ពុជា (CAVAC)